# កំណត់ហេតុព័ត៌មានពលករចំណាកស្រុក

លេខ # ២៩ – ខែមីនា ២០១៦

ការចេញផ្សាយកំណត់ហេតុព័ត៌មានពលករចំណាកស្រុកនេះជារបស់អង្គការ IOM ដែលផ្តល់ព័ត៌មានអំពី ការបន្តការចុះឈ្មោះពលករចំណាកស្រុកនៅក្នុងវិស័យនេសាទនិងវិស័យកែច្នៃគ្រឿងសមុទ្រ។ ការគ្រប់គ្រងពលករចំណាកស្រុកនៅក្រោយថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦។ ការចុះឈ្មោះពលករចំណាកស្រុកដោយអនុលោមតាមសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រី ដែលអនុម័តិនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ ។ បទបញ្ជាក្រសួងស្តីអំពីការហាមឃាត់នៅកន្លែងធ្វើការមិនឲ្យទទួលយកក្មេងក្រោមអាយុ ១៨ ឆ្នាំ រាប់ត្រឹមឆ្នាំ២០១៦។ សេចក្តីណែនាំតាមនីតិវិធីសម្រាប់ចល័តភាពនៃពលករជំនាញនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដោយយោងទៅតាមកិច្ចព្រមព្រៀងទទួលស្គាល់ប្រជាជាតិអាស៊ានទៅវិញទៅមក (MRAs)។ បទបញ្ជាលេខ ១/២៥៥៨ របស់ក្រសួងមហាផ្ទៃ ស្តីអំពីការហាមឃាត់ការចូលមកជាថ្មីនៃជនបរទេសដែលស្នាក់នៅហួសពេលកំណត់ និងទិន្នន័យស្ថិតិអំពីពលករ ចំណាកស្រុកដែលបានចុះឈ្មោះត្រឹមត្រូវ។

## 1. ការបន្តការចុះឈ្មោះពលករចំណាកស្រុកនៅក្នុងវិស័យនេសាទនិងវិស័យកែច្នៃគ្រឿងសមុទ្រ

នៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈរដ្ឋមន្ត្រីបានអនុម័តលើសេចក្តីព្រាងច្បាប់របស់ក្រសួងការងារ ដើម្បីបន្ត**ការចុះឈ្មោះពលករចំណាកស្រុកដែលមកពីកម្ពុជា ឡាវ និងភូមា** ដែលចូលមកធ្វើការនៅក្នុងវិស័យនេសាទ ដោយរាប់បញ្ចូលទាំងកូនអាយុក្រោម ១៨ ឆ្នាំដែរ។

**1)** ចំពោះវិស័យនេសាទ ការបន្តការចុះឈ្មោះសម្រាប់ពលករចំណាកស្រុកជាជនជាតិខ្មែរ ឡាវ និងភូមា

ដោយរាប់បញ្ចូលទាំងកូនអាយុក្រោម ១៨ ឆ្នាំ គឺបើកចាប់ពីថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦។ ពលករចំណាកស្រុកដែលបានចុះឈ្មោះក្នុងអំឡុងពេលនេះ មានសិទ្ធិធ្វើការនៅក្នុងប្រទេសថៃ ដោយរាប់ពីថ្ងៃទទួលបានការអនុញ្ញាតរហូតដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧។

**2)** ចំពោះវិស័យកែច្នៃគ្រឿងសមុទ្រ ការបន្តការចុះឈ្មោះសម្រាប់ពលករចំណាកស្រុកជាជនជាតិខ្មែរ ឡាវ និង ភូមា ដោយរាប់បញ្ចូលទាំងកូនអាយុក្រោម ១៨ ឆ្នាំ គឺបើកចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១០១៦ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៦។ ពលករចំណាកស្រុកដែលបានចុះឈ្មោះក្នុងអំឡុងពេលនេះ មានសិទ្ធិធ្វើការនៅក្នុងប្រទេសថៃ ដោយរាប់ពីថ្ងៃទទួលបានការអនុញ្ញាតរហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៧។

## ២. ការគ្រប់គ្រងពលករចំណាកស្រុកក្រោយថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦ គណៈរដ្ឋមន្ត្រីបានអនុម័តិគោលការណ៍គ្រប់គ្រងពលករចំណាកស្រុកនៅក្នុងឆ្នាំ២០១៦ ដែលបានស្នើដោយក្រសួងការងារដូចមានចែងនៅខាងក្រោម។

ពលករចំណាកស្រុកមកពីប្រទេសកម្ពុជា ឡាវ និងភូមា មានសិទ្ធិស្នាក់នៅជាបណ្ដោះអាសន្នក្នុងព្រះរាជាណាចក្រថៃ ដើម្បីឆ្លងកាត់ការពិនិត្យសុខភាព ទិញធានារ៉ាប់រងសុខភាព ចុះឈ្មោះនិងដាក់ពាក្យសុំប័ណ្ណការងារក្នុងរយៈពេល ១២០ថ្ងៃ (១ មេសា – ២៩ កក្កដា ២០១៦)។ ពលករចំណាកស្រុកដែលបានចុះឈ្មោះក្នុងអំឡុងពេលនេះ នឹងទទួលបានសិទ្ធិធ្វើការនៅក្នុងប្រទេសថៃចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨។ ប្រភេទពលករចំណាកស្រុកដែលមានលក្ខណៈគ្រប់គ្រាន់គឺ៖

1) ពលករចំណាកស្រុកជាជនជាតិខ្មែរ ឡាវ និងភូមា ដោយរាប់បញ្ចូលទាំងកូនអាយុក្រោម១៨ឆ្នាំ ដែលបានទទួលសិទ្ធិធ្វើការជាបណ្ដោះអាសន្ននៅក្នុងប្រទេសថៃ ដោយស្របទៅតាមបទបញ្ជានៃក្រុមប្រឹក្សាជាតិដើម្បីសន្តិភាពនិងសណ្ដាប់ធ្នាប់ (NCPO) ចេញនៅឆ្នាំ២០១៤។ ទាំងនេះជាអ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកចំនួន ១,៦២៦,២៣៥ នាក់។

២) ពលករចំណាកស្រុក ដោយរាប់បញ្ចូលទាំងកូនអាយុក្រោម១៨ឆ្នាំ ដែលកាន់លិខិតឆ្លងដែនឬឯកសារធ្វើដំណើរ ហើយបានបំពេញដំណើរបញ្ជាក់សញ្ជាតិ រួមទាំងបានបញ្ចប់ការបំពេញការងាររបស់ពួកគេពីបួនទៅប្រាំមួយឆ្នាំ។

ពលករចំណាកស្រុកដែលត្រូវបានជ្រើសរើសក្រោមអនុស្សារណៈយោគយល់គ្នា (MOU) និងពលករនៅក្នុង វិស័យនេសាទដែលមកពីការចុះឈ្មោះពីរលើកចុងក្រោយ មិនត្រូវរាប់បញ្ចូលនៅក្នុងផែនការមួយនេះទេ ៗ

ដំណើរការបញ្ជាក់សញ្ជាតិនឹងអនុវត្តទៅតាមសំណើរបស់ប្រទេសដើមកំណើត ៗ ក្រសួងការងារ អាចនឹងចរចារជាមួយប្រទេសដើមកំណើតទាំងនោះដោយមានកិច្ចសហប្រតិបត្តិការពីក្រសួងកិច្ចការបរទេស ៗ

## 3. ការចុះឈ្មោះពលករចំណាកស្រុកដោយអនុលោមតាមសេចក្តីសម្រេចរបស់គណ:រដ្ឋមន្ត្រី ដែលអនុម័តនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៦

ការចុះឈ្មោះពលករចំណាកស្រុក បើកទទួលចំនួន១២០ថ្ងៃ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ រហូតដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ ៗ ពលករចំណាកស្រុកដែលបានចុះឈ្មោះក្នុងអំឡុងពេលនេះ និងមានសិទ្ធិធ្វើការនៅក្នុងប្រទេសថៃ ពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៨ ៗ

1. **ពលករចំណាកស្រុកពីរក្រុមដែលអាចចុះឈ្មោះបាន**

1.1 **អ្នកកាន់ប័ណ្ណពណ៌ផ្កាឈូក**

1.1.1 អ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកដោយស្របទៅតាមគោលនយោបាយរបស់ ក្រុមប្រឹក្សាជាតិដើម្បីសន្តិភាព

និងសណ្តាប់ធ្នាប់ (NCPO) ៗ កាលបរិច្ឆេទអស់សុពលភាពស្ថិតនៅខ្នងប័ណ្ណ អាចជាឆ្នាំ២០១៤ ឬ

២០១៥ ៗ

1.1.2 អ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកដោយស្របទៅតាមគោលនយោបាយរបស់ ក្រុមប្រឹក្សាជាតិដើម្បីសន្តិភាព

និងសណ្តាប់ធ្នាប់ (NCPO) ដែលបានប្តូរប័ណ្ណថ្មីហើយផុតកំណត់នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ ២០១៦ ៗ

1.1.3 អ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកដែលមិនអាចចុះឈ្មោះក្នុងកំឡុងពេលនេះ៖

- ជាអ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកដែលផុតកំណត់មុនឆ្នាំ២០១៤
- ជាពលករចំណាកស្រុកដែលចុះឈ្មោះនៅក្នុងវិស័យនេសាទនិងវិស័យកែច្នៃគ្រឿងសមុទ្រ៖

**<u>វិស័យនេសាទ</u>**

- នៅខាងក្រោយប័ណ្ណពណ៌ផ្កាឈូកមានកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ ២០១៦

- នៅខាងក្រោយប័ណ្ណពណ៌ផ្កាឈូកមានកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ ២០១៧

<u>**វិស័យកែច្នៃគ្រឿងសមុទ្រ**</u>

- នៅខាងក្រោយប័ណ្ណពណ៌ផ្កាឈូកមានកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០១៦
- នៅខាងក្រោយប័ណ្ណពណ៌ផ្កាឈូកមានកាលបរិច្ឆេទផុតកំណត់នៅថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ ២០១៧

1.2 **អ្នកកាន់ឯកសារដែលចេញដោយប្រទេសកំណើតរបស់ពួកគេ**

1.2.1 គ្រប់ពលករជាជនជាតិខ្មែរ ឡាវ និងភូមា ដែលបានបំពេញបែបបទបញ្ជាក់សញ្ជាតិ ដោយរួមបញ្ចូលទាំង

កូនរបស់ពួកគេដែលមានអយុក្រោម១៨ឆ្នាំ ដែលមានភ្ជាប់ឯកសារដូចខាងក្រោម៖

**លិខិតឆ្លងដែន** – PP

- លិខិតឆ្លងដែនបណ្តោះអាសន្ន – TP
- លិខិតឆ្លងដែនធ្វើដំណើរ – TD
- លិខិតបញ្ជាក់អត្តសញ្ញាណ – CI

1.2.2 លក្ខខណ្ឌនីតិវិធី

- អ្នកដែលអាចដាក់ពាក្យស្នើសុំប័ណ្ណការងារ៖ ជាពលករចំណាកស្រុកដែលមានឯកសារក្នុង ចំណុច

  1.2.1 អស់សុពលភាព មានឯកសារសុពលភាពតែគ្មានទិដ្ឋការ មានទិដ្ឋការសុពលភាពឬ អស់សុពលភាព; ជាពលករចំណាកស្រុកដែលបានឆ្លងកាត់ដំណើរការបញ្ជាក់សញ្ជាតិ និង បានបញ្ចប់ការងាររយៈពេល បួននិងប្រាំមួយឆ្នាំ; និងអ្នកដែលមានឯកសារប្រថាប់ត្រាអនុស្សារណៈយោគយល់ ។ វៀរលែងតែពលករជាជនជាតិខ្មែរ ឡាវ និងភូមា ដែលត្រូវបាន ជ្រើសរើសដំបូងតាមអនុស្សារណៈយោគយល់ គឺមិនអាចដាក់ពាក្យស្នើសុំបានទេ ។
- ក្នុងករណីអ្នកកាន់ប័ណ្ណពណ៌ផ្កាឈូកដែលស្ថិតក្នុងចំណុចទី 1.1.1 និង 1.1.2 បានបាត់ប័ណ្ណ នោះពួក

  គេត្រូវបានទាមទារឲ្យស្នើសុំច្បាប់ចម្លងនៃ ត៖ 38/1 ពីមន្ត្រីចុះឈ្មោះនៅតាមសង្កាត់/ តំបន់ ដើម្បីទុកជាឯកសារសម្គាល់អត្តសញ្ញាណ ។ មានតែច្បាប់ចម្លងដើមនៃ ត៖ 38/1

ប៉ុណ្ណោះដែលអាចប្រើបាននៅកន្លែងចុះឈ្មោះ (មិនអាចប្រើច្បាប់ថតចម្លងបានទេ)។ ចំពោះអ្នកកាន់ឯកសារដែលចេញដោយប្រទេសកំណើតដូចមានចែងក្នុងចំណុច 1.2.1 កាលបើបាត់ឯកសារទាំងនេះ ពួកគេមិនអាចប្រើច្បាប់ផ្ទួតផ្ទាត់ណាមួយបានទេ។ ពលករចំណាកស្រុកត្រូវតែដាក់ស្នើឯកសារអមនានាដូចជា ប័ណ្ណការងារមានបញ្ជាក់ឈ្មោះពេញដែលមានការប្រកបស្រដៀងទៅនឹង TP, TD ឬ CI។

- ពលករចំណាកស្រុកដែលមានបំណងធ្វើការជាមួយនិយោជកដដែលដែលមានបញ្ជាក់លើខ្នងប័ណ្ណ

  ពណ៌ផ្កាឈូក ឬក៏និយោជកណាដែលមានឈ្មោះខុសពីអ្នកនៅលើខ្នងប័ណ្ណនោះ ពួកគេអាចចុះឈ្មោះនិងដាក់ពាក្យសុំប័ណ្ណការងារបាន។
- ពលករចំណាកស្រុកដែលមានអាយុក្រោម១៨ឆ្នាំ មិនត្រូវបានអនុញ្ញាតឲ្យធ្វើការនោះទេ លើកលែងតែមានការងារណាដែលមានចែងដោយច្បាប់។

2. **ជំហាននីតិវិធី**

ពលករចំណាកស្រុកដែលមានលក្ខណៈគ្រប់គ្រាន់អាចដាក់ពាក្យបាន ត្រូវតែឆ្លងកាត់ការពិនិត្យសុខភាពពីមន្ទីរពេទ្យដែលកំណត់ដោយ ក្រសួងសុខាភិបាលសាធារណៈ (MoPH) រវាងថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦។ តម្លៃពិនិត្យសុខភាពគឺ ៥០០ បាត។ តម្លៃធានារ៉ាប់រងសុខភាពរយៈពេលពីរឆ្នាំគឺ ៣,២០០ បាត។ ពលករចំណាកស្រុកណាដែលត្រូវបានធានាក្រោមមូលនិធិសន្តិសុខសង្គម មិនចាំបាច់ទិញធានារ៉ាប់រងសុខភាពនោះទេ។ ពលករចំណាកស្រុកណាដែលធ្វើការនៅក្នុងវិស័យដែលត្រូវទាមទារឲ្យមានសមាជិកភាពនៅក្នុងមូលនិធិសន្តិសុខសង្គម តែមិនទាន់បានធានាខ្លួនឯងទេ គឺត្រូវទិញធានារ៉ាប់រងសុខភាពរយៈពេល ៩០ ថ្ងៃ។

**<u>ទីតាំងពិនិត្យសុខភាព</u>**

1. មានមន្ទីរពេទ្យចំនួន ៧ នៅរាជធានីបាងកក។
   - មន្ទីរពេទ្យកណ្តាល (Klang Hospital)
   - មន្ទីរពេទ្យនព្វរតន៍ (Nopparat Hospital)
   - មន្ទីរពេទ្យឡឺតស៊ីន (Lerdsin Hospital)
   - មន្ទីរពេទ្យរាជវិថី (Rajavithi Hospital)
   - មន្ទីរពេទ្យថាក់ស៊ីន (Taksin Hospital)
   - មន្ទីរពេទ្យចម្រើនក្រុងព្រះចក្រ (Charoenkrung Pracharak Hospital)

- មន្ទីរពេទ្យវជីរ៉ា (Vajira Hospital)

ខ. រីឯនៅតាមបណ្តាខេត្តវិញ ក្រសួងសុខភាពសាធារណ: ជាអ្នកសម្រេចចិត្តទៅលើការជ្រើសរើសទីតាំង ។

## ខ.ខ តម្លៃពាក្យសុំប័ណ្ណធ្វើការ

ខ.ខ.1 ក្រោយពេលពលករចំណាកស្រុកបានឆ្លងផុតការពិនិត្យសុខភាពដោយបញ្ជាក់ថាគាត់មិនមានជំងឺ

ហាមឃាត់ណាមួយនោះទេ នោះគាត់ត្រូវបង់ថ្លៃពាក្យស្នើសុំប័ណ្ណការងារនៅបញ្ជរបម្រើសេវា ឬក៏នៅតាមការិយាល័យការងារខេត្តណាមួយ ឬក៏នៅការិយាល័យការងារនៅបាងកក 1-10 ។ ប័ណ្ណការងាររយ:ពេលពីរឆ្នាំមានតម្លៃ ១,៨០០ បាត ។ តម្លៃពាក្យស្នើសុំគឺ ១០០ បាត ។ សរុបគឺ ១,៩០០ បាត ។ គាត់ត្រូវនាំមកជាមួយនូវលិខិតបញ្ជាក់ដើមនៃការពិនិត្យសុខភាព ដោយមានភ្ជាប់ប័ណ្ណពណ៌ផ្កាឈូក ឬ PP/TP/TD/CI ។

ក្នុងករណីពលករចំណាកស្រុកណាមួយបាត់ឯកសាររបស់គាត់ នោះគាត់ត្រូវបង់ថ្លៃនៅការិយាល័យការងារខេត្តណាមួយ ឬក៏នៅការិយាល័យការងារនៅបាងកក 1-10 ដើម្បីឲ្យមន្ត្រីទទួលបន្ទុកធ្វើការត្រួត  ពិនិត្យស្ថានភាពជាពលករចំណាកស្រុក មុនពេលពួកគេប្រមូលថ្លៃផ្សេងៗទៀត ។

និយោជកនិងពលករចំណាកស្រុក ត្រូវតែពិនិត្យថាពលករនោះពិតជាមានលក្ខណ:គ្រប់គ្រាន់ មុនពេលបង់ថ្លៃចំណាយ ។ ប្រសិនបើពលករនោះមិនមានលក្ខណ:គ្រប់គ្រាន់អាចចុះឈ្មោះបានទេ នោះមិនមានសំណងចំពោះថ្លៃដែលបានបង់រួចហើយឡើយ ។

### ខ.ខ.ខ ទីតាំងបង់ថ្លៃចំណាយ

1. បញ្ជរបម្រើសេវា

ពលករចំណាកស្រុកម្នាក់ៗនឹងត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ១០០ បាត, ប័ណ្ណធ្វើការរយ:ពេលពីរឆ្នាំថ្លៃ ១,៨០០ បាត, ហើយនិងថ្លៃបញ្ជរបម្រើសេវាចំនួន ១០ បាត ។ សរុបគឺ ១,៩១០ បាត ។ ក្នុងករណី

ណាដែលនិយោជកមានពលករចំណាកស្រុកច្រើន សូមមេត្តាស្នើសុំការណាត់ជួបបញ្ជូនបម្រើសេវាឲ្យរួចជាមុន។

<u>ពលករចំណាកស្រុកនឹងទទួលបាន៖</u>

- បង្កាន់ដៃ និង ប័ណ្ណណាត់ជួប
- សារ SMS ដល់លេខទូរសព្ទដែលបានផ្តល់ដោយពលកររបស់និយោជក ដែលបញ្ជាក់អំពីការបង់ប្រាក់

ខ. ការិយាល័យការងារខេត្ត និង ការិយាល័យការងារនៅបាងកក 1-10

ពលករចំណាកស្រុកម្នាក់ៗនឹងត្រូវបង់ថ្លៃពាក្យស្នើសុំចំនួន ១០០ បាត និងប័ណ្ណការងាររយៈពេលពីរឆ្នាំថ្លៃ ១,៨០០ បាត។ សរុបគឺ ១,៩០០ បាត។ មិនមានកម្រៃសេវាកម្មណាមួយទេ។ ក្នុងករណីណាដែលនិយោជកមានពលករចំណាកស្រុកច្រើន សូមមេត្តាស្នើសុំការណាត់ជួបបញ្ជូនបម្រើសេវាឲ្យរួចជាមុន។

<u>ពលករចំណាកស្រុកនឹងទទួលបាន៖</u>

- បង្កាន់ដៃ
- ប័ណ្ណណាត់ជួប

### 2.3 ឯកសារអមជាមួយពាក្យស្នើសុំប័ណ្ណការងារ

ពាក្យស្នើសុំការងារត្រូវមានភ្ជាប់ជាមួយ (តអ8) ឯកសារអមផ្សេងៗដូចខាងក្រោម។

1. លិខិតបញ្ជាក់ដើមអំពីសុខភាព
2. ឯកសាររបស់និយោជកដូចជា អត្តសញ្ញាណបណ្ណ / ឯកសារចុះបញ្ជីផ្ទះឬក្រុមហ៊ុន ប្រសិនបើមាន។
3. កិច្ចសន្យាការងារ
4. លិខិតបញ្ជាក់ការងារ
5. ឯកសារចុះបញ្ជីផ្ទះ ឬឯកសារស្របច្បាប់ ឬក៏ឯកសារផ្សេងៗដែលបញ្ជាក់អំពីទីកន្លែងការងាររបស់ ពលករចំណាកស្រុក
6. ផែនទីកន្លែងធ្វើការ
7. រូបថត 3 x 4 សង់ទីម៉ែត្រចំនួនពីរសន្លឹក

8. ប័ណ្ណដែលចេញដោយបញ្ជរបម្រើសេវា ឬក៏បង្កាន់ដៃដែលចេញដោយការិយាល័យការងារខេត្ត ឬ

ការិយាល័យការងារនៅបាងកក

ក្នុងករណីណាដែលត្រូវដាក់ពាក្យស្នើសុំលើសពីមួយ នោះគ្រប់ការដាក់ត្រូវមួយភ្ជាប់សំណុំឯកសាររបស់និយោជកទៅក្នុងពាក្យស្នើសុំនីមួយៗ។ កិច្ចសន្យាការងារត្រូវតែត្រូវបានរៀបចំដោយភាគីនិយោជកនិងភាគីពលករ ចំណាកស្រុក។ ក្នុងពាក្យស្នើសុំត្រូវការលិខិតបញ្ជាក់ការងារតែមួយច្បាប់ប៉ុណ្ណោះ (ឯកសារដទៃរបស់និយោជកក៏យ៉ាងដូច្នេះដែរ) ដោយមានសម្គាល់នៅក្រោមលិខិតបញ្ជាក់នោះថា «បញ្ជាក់ដល់ការងាររបស់ពលករចំណាកស្រុកដែលមាននៅក្នុងបញ្ជីភ្ជាប់មកជាមួយនេះ»។ បញ្ជីឈ្មោះពលករចំណាកស្រុកក៏ត្រូវតែភ្ជាប់ជាមួយដែរ។

**2.4 និយោជកជាមួយពលករចំណាកស្រុក ឬ ពលករចំណាកស្រុក ដាក់ពាក្យដោយភ្ជាប់ឯកសារដែលរៀបចំរួចស្រេចទៅមន្ត្រីនៅមជ្ឈមណ្ឌលសេវាមួយកន្លែង។** ពលករចំណាកស្រុកនឹងទទួលបានប័ណ្ណការងារនៅថ្ងៃដដែលក្រោយដាក់ពាក្យរួច។ ពលករត្រូវតែបង់ថ្លៃប័ណ្ណពណ៌ផ្កាឈូកនិងថ្លៃចុះឈ្មោះ (តម 38/1) សរុបគឺ ៨០ បាត។

**2.5 ការផ្លាស់ប្តូរ និយោជក/ទីតាំង/កន្លែងធ្វើការ**

- មិនមានការអនុញ្ញាតឲ្យផ្លាស់ប្តូរនិយោជកសម្រាប់ពលករចំណាកស្រុកណាដែលបានចុះឈ្មោះនិងទទួលបានប័ណ្ណការងារនៅក្នុងអំឡុងពេលចុះឈ្មោះពីថ្ងៃទី១ ខែមេសា ដល់ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៦ នៅមជ្ឈមណ្ឌលសេវាមួយកន្លែង ណាមួយនោះទេ។
- ករណីផ្លាស់ប្តូរនិយោជក ការចុះឈ្មោះនឹងត្រូវបានទទួលអនុញ្ញាតបន្ទាប់ពីរយៈពេលកន្លងផុតទៅ លើលក្ខខណ្ឌដូចខាងក្រោម។

<u>និយោជកបញ្ចប់កិច្ចសន្យាការងារ</u>

- និយោជកបិទទ្វារលែងរកស៊ី ឬបិទផ្នែកណាមួយដែលពាក់ព័ន្ធនឹងកម្លាំងពលកម្មចំណាកស្រុក។
- និយោជកធ្វើអំពើហិង្សា។
- និយោជកពន្យារពេលឲ្យប្រាក់ឈ្នួល ឬរំលោភលើច្បាប់ការពារពលកម្ម។

តម្លៃនៅក្នុងករណីផ្លាស់ប្តូរនិយោជកនឹងអនុលោមតាមច្បាប់ដែលបានចែង។ ក្រោយពេលពលករចំណាកស្រុកបានផ្លាស់ប្តូរនិយោជករួចរាល់ហើយ គាត់ត្រូវតែរាយការណ៍ទៅការិយាល័យចុះឈ្មោះតាមសង្កាត់ ឬ ការិយាល័យចុះឈ្មោះតាមតំបន់ ដើម្បីផ្លាស់ប្តូរប័ណ្ណពណ៌ផ្កាឈូករបស់និងប័ណ្ណការងាររបស់ពួកគេ (គឺព័ត៌មាននៅខ្នងប័ណ្ណ)។

<u>នីតិវិធីក្នុងការផ្លាស់ប្តូរនិយោជក</u>

1. ពលករចំណាកស្រុកឬក៏និយោជកថ្មីត្រូវតែផ្តល់ភ័ស្តុតាងអំពីការបញ្ចប់កិច្ចសន្យា, ការបិទទ្វារលែងរកស៊ី, ឬ
   ពាក្យប្តឹងនិយោជកមុន (មើល "និយោជកបញ្ចប់កិច្ចសន្យាការងារ" នៅទំព័រទី ៧)។
2. នាយកដ្ឋានការពារពលកម្មនិងសុខមាលភាព នឹងដោះស្រាយពាក្យប្តឹងនិយោជកមុនក្នុងករណីពាក់ព័ន្ធ
   នឹងអំពើហិង្សា និងការពន្យារការបង់ប្រាក់ឈ្នួលឬការរំលោភបំពានលើច្បាប់ការពារពលកម្ម ដោយយោង
   ទៅតាមឱសានវាទ។ កាលបើនិយោជកត្រូវបានរកឃើញថាមានកំហុស នោះនឹងមិនត្រូវបាន
   អនុញ្ញាតឲ្យជួលពលករចំណាកស្រុកចំនួនពីរឆ្នាំ។
3. ពលករចំណាកស្រុកណាដែលផ្លាស់ប្តូរនិយោជកដោយគ្មានយុត្តិកម្មសមស្រប នឹងមិនត្រូវបានអនុញ្ញាតឲ្យ
   ធ្វើការនៅប្រទេសថៃចំនួនពីរឆ្នាំ ហើយត្រូវតែត្រឡប់ទៅប្រទេសកំណើតវិញ។
   ប្រសិនបើគាត់មានបំណងមកធ្វើការនៅប្រទេសថៃ នោះគាត់អាចដាក់ពាក្យស្នើសុំការងារ
   ក្រោមអនុស្សារណៈយោគយល់គ្នា។
4. និយោជកដែលជួលពលករចំណាកស្រុកខុសច្បាប់ ត្រូវទទួលការកាត់ទោសដោយយោងទៅតាមឱសាន
   វាទ។

**ទីតាំងមជ្ឈមណ្ឌលសេវាមួយកន្លែងនៅបាងកក**

| ទីតាំង | ក្រុង/សង្កាត់ |
| --- | --- |
| Laksi IT Square, T Floor.<br>ផ្លូវឆាងវ៉ឌ្ឍនា, សង្កាត់ឡាក់ស៊ី | សង្កាត់លេខ១២ (ចតុចក្រ, ដនមឿង, បាងសឿ, បាងខេន, និងឡាក់ស៊ី)<br>សង្កាត់លេខ១៣ (ឌីនដែង, រាជថេវី), និង ហួយឃ្វាង) |
| អគារ Van Center, ស្ថានីយឡាន | សង្កាត់លេខ១៥ (ខ្លងសាង, ធនបុរី, បាងកកន៉យ, និង បាងផ្លាត) |

| ទីតាំង | ក្រុង/សង្កាត់ |
|---|---|
| ក្រុងបាងកក (ភាគខាងត្បូង)<br>ផ្លូវបរមរាជឈុណ្ណានី, សង្កាត់តៈលីងឆាន | សង្កាត់លេខ៦ (តៈលីងឆាន, ថាវីវឌ្ឍនា, បាងខែ, ផាសីចារើន, ណងខាម, និង ផុងខាម)<br>សង្កាត់លេខ៧ (ចមថង, ធុងគ្រុ, បាងឃុនធាង, បាងបន, និង រាជបូរណៈ) |
| សួនថាន់យ៉ា<br>ផ្លូវស្រីនគរិន្ទ្រ, សង្កាត់សួនលួង | សង្កាត់លេខ៨ (ខ្លងទើយ, បាងណា, ប្រះខានង, វឌ្ឍនា, សួនលួង, និង ប្រវេស)<br>សង្កាត់លេខ៩ (ខាន់ណាយ៉ាវ, បាងកាពិ, ឡាតប្រាវ, វ៉ាងថង់ឡាង, និង បឹងគុំ) |
| ចំណុចប្រសព្វផ្សារណងចក<br>ផ្លូវសុរិន្ទាវង្ស, សង្កាត់ណងចក | សង្កាត់លេខ១០ (ខ្លងសាមវ៉ា, មីនបុរី, ឡាតក្របាង, សផាន ស៊ុង, ណងចក និង ខែសខែម៉) |

<u>សម្គាល់៖</u> សង្កាត់លេខ១ (ឌុស៊ីដ, ភ្នំប្រាប និង សំផន្ទាវង្ស)

សង្កាត់លេខ៤ (បាងរ៉ាក់, បទុមវ័ន, យ៉ាន់ណាវ៉ា, សាថត និង បាងខូខែឡម) អាចចុះឈ្មោះនៅមជ្ឈមណ្ឌល

សេវាមួយកន្លែង ណាមួយក៏បាន។

ឯកសារទាក់ទងនឹងការចុះឈ្មោះនិងប័ណ្ណការងារ អាចរកបាននៅ http://www.doe.go.th/node/1322

## 4. បទបញ្ជាលេខ ១/២៥៥៨ របស់ក្រសួងមហាផ្ទៃ ស្តីអំពីការហាមឃាត់ការចូលមកជាថ្មីនៃជនបរទេសដែលស្នាក់នៅហួសពេលកំណត់

លោកនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ទទួលបន្ទុកផ្នែកសណ្តាប់ធ្នាប់ជាតិនិងសាធារណៈ បានចេញបទបញ្ជាលេខ ១/២៥៥៨ កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៥ ដោយយោងទៅលើជំពូក ១៦ នៃច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៧៩ ក្នុងគោលបំណងហាមឃាត់ការចូលមកជាថ្មីនៃជនបរទេសណាដែលបានស្នាក់នៅហួសពេលកំណត់។

1) **ករណីដែលស្នាក់នៅហួសពេលកំណត់ ហើយព្រមចូលខ្លួនជួបអាជ្ញាធរ**

1.1 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ លើសពី ៩០ ថ្ងៃ នឹងត្រូវហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលមួយឆ្នាំក្រោយពេលបណ្តេញចេញ។

1.2 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ លើសពីមួយឆ្នាំ នឹងត្រូវហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលបីឆ្នាំក្រោយពេលបណ្តេញចេញ។

1.3 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ លើសពីបីឆ្នាំ និងត្រូវហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលប្រាំឆ្នាំក្រោយពេលបណ្តេញចេញ។
1.4 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ លើសពីប្រាំឆ្នាំ និងត្រូវហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលដប់ឆ្នាំក្រោយពេលបណ្តេញចេញ។

2) **ករណីត្រូវចាប់ខ្លួនព្រោះការស្នាក់នៅហួសពេលកំណត់**

2.1 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ តិចជាងមួយឆ្នាំ និងត្រូវ

ហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលប្រាំឆ្នាំក្រោយពេលបណ្តេញចេញ។

2.2 ជនបរទេសណាដែលបានស្នាក់នៅផុតពេលកំណត់នៅក្នុង ព្រះរាជាណាចក្រថៃ ច្រើនជាងមួយឆ្នាំ និងត្រូវ

ហាមមិនឲ្យចូលមកជាថ្មីក្នុងរយៈពេលដប់ឆ្នាំក្រោយពេលបណ្តេញចេញ។

3) **បទបញ្ជារបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃនេះ មិនអនុវត្តចំពោះករណីដូចខាងក្រោម៖**

3.1 ជនបរទេសដែលបានចាកចេញពីព្រះរាជាណាចក្រ មុនពេលគ្រប់អាយុ ១៨ ឆ្នាំ

3.2ជនបរទេសដែលបានចាកចេញពីព្រះរាជាណាចក្រ មុនពេលបទបញ្ជានេះចេញផ្សាយ

បទបញ្ជានេះចូលជាធរមាននៅ ៩០ ថ្ងៃក្រោយប្រកាសឲ្យប្រើនៅក្នុងសេចក្តីប្រកាសរបស់រដ្ឋាភិបាល ។

## 5. បទបញ្ជាក្រសួងស្តីអំពីការហាមឃាត់កន្លែងធ្វើការមិនឲ្យទទួលយកក្មេងក្រោមអាយុ ១៨ ឆ្នាំរាប់ត្រឹមឆ្នាំ២០១៦

ដោយយោងតាមជំពូក ៦ នៃច្បាប់ការពារពលកម្ម ឆ្នាំ១៩៩៨ និងជំពូក ៥០ (៤) ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ការពារពលកម្ម (លេខ២) ឆ្នាំ២០០៨, ក្រសួងការងារបានចេញផ្សាយបទបញ្ជាក្រសួងស្តីអំពីការហាមឃាត់កន្លែងធ្វើការមិនឲ្យទទួលយកក្មេងក្រោមអាយុ ១៨ ឆ្នាំឲ្យចូលធ្វើការនៅក្នុង៖

1) រោងចក្រកែច្នៃគ្រឿងសមុទ្រ យោងទៅតាមច្បាប់ដែលទាក់ទងនឹងរោងចក្រ

2) កន្លែងកែច្នៃគ្រឿងសមុទ្រ យោងទៅតាមសេចក្តីសម្រេចស្តីអំពីការសង្គ្រោះផលផល ឆ្នាំ២០១៥

កន្លែងការងារដទៃទៀតដែលមិនត្រូវទទួលនិយោជិតក្រោមអាយុ ១៨ ឆ្នាំមានដូចជា ទីសត្តឃាត រោងល្បែងស៊ីសង ទីកម្សាន្ត ដោយយោងទៅតាមច្បាប់ស្តីអំពីការកម្សាន្ត ហើយរួមទាំងកន្លែងធ្វើការដទៃទៀតដោយយោងទៅតាមបទបញ្ជាក្រសួង។

## 6. សេចក្តីណែនាំតាមនីតិវិធីសម្រាប់ចល័តភាពនៃពលករជំនាញនៅក្នុង AEC ដោយយោងទៅតាម MRAs

នាយកដ្ឋានការងារ (DOE) នៃក្រសួងការងារ (MoL) នៃព្រះរាជាណាចក្រថៃ បានអភិវឌ្ឍសេចក្តីណែនាំតាមនីតិវិធីសម្រាប់ចល័តភាពនៃពលករជំនាញនៅក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ដោយស្របទៅតាមកិច្ចព្រមព្រៀងទទួលស្គាល់ប្រជាជាតិអាស៊ានទៅវិញទៅមក (MRAs)៖

1. ប្រទេសជាសមាជិកអាស៊ានរួមមាន **ប្រ៊ុយណេ, កម្ពុជា, ឥណ្ឌូនេស៊ី, ឡាវ, ម៉ាឡេស៊ី, ភូមា, ភីលីពីន, ថៃ, សិង្ហបុរី, និងវៀតណាម។**
2. បទប្បញ្ញត្តិក្នុងការចេញប័ណ្ណការងារទៅឲ្យពលករជំនាញមកពីប្រទេសជាសមាជិកអាស៊ានមានដូចតទៅ៖

2.1 ច្បាប់អ្នកធ្វើការជាជនបរទេស ឆ្នាំ២០០៨ – ជនបរទេសត្រូវតែប្រើ «ទិដ្ឋការមិនមែនអន្តោប្រវេសន៍ប្រភេទ B» ដើម្បីចូលមកក្នុងព្រះរាជាណាចក្រថៃ។

2.2 សេចក្តីសម្រេចឆ្នាំ១៩៧៩ ដោយហាមឃាត់ការផ្តល់ការងារនិងជំនាញចំនួន ៣៩ ទៅឲ្យជនបរទេស

2.3 សេចក្តីណែនាំរបស់នាយកដ្ឋានការងារ ឆ្នាំ១៩៧៩ ស្តីអំពីការចេញប័ណ្ណការងារទៅឲ្យជនបរទេស

2.4 អ្នកធ្វើការជាជនបរទេសត្រូវមាន **អាជ្ញាប័ណ្ណឬលិខិតបញ្ជាក់ចេញពីសមាគមវិជ្ជាជីវៈណាមួយដែលទាក់ទងនឹងជំនាញខ្លួន** ដែលស្របទៅតាមកិច្ចព្រមព្រៀងទទួលស្គាល់ប្រជាជាតិអាស៊ានទៅវិញទៅមក (MRAs)។

| វិជ្ជាជីវៈ | សមាគម (ប្រទេសថៃ) |
|---|---|
| វិស្វករ | ក្រុមប្រឹក្សាវិស្វករ |
| រដ្ឋករ (អ្នកស្ទង់ដី) | ក្រុមប្រឹក្សាវិស្វករ |
| ស្ថាបត្យករ | ក្រុមប្រឹក្សាស្ថាបត្យករ |

| វិជ្ជាជីវៈ | សមាគម (ប្រទេសថៃ) |
|---|---|
| វេជ្ជបណ្ឌិត | ក្រុមប្រឹក្សាសុខាភិបាល, ក្រសួងសុខភាពសាធារណៈ |
| ទន្តពេទ្យ | ក្រុមប្រឹក្សាសុខាភិបាល, ក្រសួងសុខភាពសាធារណៈ |
| គិលានុបដ្ឋាក | ក្រុមប្រឹក្សាគិលានុបដ្ឋាក |
| គណនេយ្យករ | សហព័ន្ធវិជ្ជាជីវៈគណនេយ្យ |
| វិជ្ជាជីវៈ ៣២ ក្នុងទេសចរណ៍<br>1. លេខាអ្នកគ្រប់គ្រង<br>2. លេខាប្រធានការិយាល័យ<br>3. អ្នកទទួលភ្ញៀវ<br>4. ការីទូរសព្ទ<br>5. អ្នកយាមទ្វារ<br>6. ប្រធានផ្នែករៀបចំផ្ទះ<br>7. អ្នកគ្រប់គ្រងផ្នែកបោកគក់<br>8. លេខាប្រធានការិយាល័យ<br>9. អ្នកបោកគក់<br>10. អ្នករៀបចំបន្ទប់<br>11. អ្នកសម្អាតកន្លែងសាធារណៈ<br>12. នាយចុងភៅ<br>13. ជំនួយការចុងភៅ<br>14. ចុងភៅ<br>15. Chef de Partie<br>16. អ្នកផ្គត់ផ្គង់គ្រឿងដុតនំ<br>17. អ្នកដុតនំ<br>18. អ្នកលក់សាច់<br>19. នាយក F&B<br>20. អ្នកគ្រប់គ្រង OutletF&B | ក្រសួងទេសចរណ៍និងកីឡា |

| វិជ្ជាជីវៈ | សមាគម (ប្រទេសថៃ) |
|---|---|
| 21. ប្រធានផ្នែកបម្រើភ្ញៀវ<br>22. អ្នកក្រឡុកស្រា<br>23. អ្នកបម្រើភ្ញៀវ<br>24. អ្នកចាត់ការទូទៅ<br>25. ជំនួយការអ្នកចាត់ការទូទៅ<br>26. អ្នកគ្រប់គ្រងជាន់ខ្ពស់<br>27. អ្នកប្រឹក្សាការធ្វើដំណើរ<br>28. អ្នកគ្រប់គ្រងផលិតផល<br>29. អ្នកគ្រប់គ្រងផ្នែកលក់និងទីផ្សារ<br>30. អ្នកគ្រប់គ្រងឥណទាន<br>31. អ្នកគ្រប់គ្រងផ្នែកលក់សំបុត្រ<br>32. អ្នកគ្រប់គ្រងផ្នែកទេសចរណ៍ | |

3. ការជួយសម្រួលដល់ការចេញប័ណ្ណការងារឲ្យពលករជំនាញដែលមកពីប្រទេសជាសមាជិកអាស៊ាន

3.1 សំណុំឯកសារពាក្យស្នើសុំត្រូវបានភ្ជាប់ជាមួយ ច្បាប់នៃការសម្រួលការចេញអាជ្ញាប័ណ្ណ ឆ្នាំ ២០១៥

3.2 **ការផ្តល់ឲ្យតាមរយៈភ្នាក់ងារពិសេស** ASEAN LANE នៅនាយកដ្ឋានការងារ**គឺធ្វើរួចនៅក្នុងពេលមួយថ្ងៃ** (ជំនួសឲ្យ ២-៣ ថ្ងៃ)។

4. ពាក្យស្នើសុំប័ណ្ណការងារត្រូវបានដាក់នៅតាមសាខាណាមួយរបស់នាយកដ្ឋានការងារ ដែលស្ថិតនៅក្បែរកន្លែងធ្វើការរបស់អ្នកដាក់ពាក្យ។

- បើនៅបាងកក សូមទាក់ទងការិយាល័យរដ្ឋបាលពលករបរទេស, នាយកដ្ឋានការងារ, ក្រសួងការងារ។
- បើនៅតាមបណ្តាខេត្ត សូមទាក់ទងការិយាល័យការងារខេត្ត។

## 7. ស្ថិតិពលករចំណាកស្រុកនៅក្នុងប្រទេសថៃ

តារាងទី១៖ ចំនួនពលករចំណាកស្រុកដែលមានសិទ្ធិធ្វើការដោយស្របច្បាប់ និងចូលមកប្រទេសថៃតាមរយៈអនុស្សារណៈយោគយល់គ្នា (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៦)

| សញ្ជាតិ | ចំនួន |
|---|---|
| ភូមា | 143,461 |
| កម្ពុជា | 117,424 |
| ឡាវ | 31,795 |
| សរុប | 292,680 |

*ប្រភព៖ ការិយាល័យរដ្ឋបាលកម្មករបរទេស, នាយកដ្ឋានការងារ, ក្រសួងការងារ*

តារាងទី២៖ ចំនួនពលករចំណាកស្រុកដែលបានពីការបញ្ជាក់សញ្ជាតិពីមុនៗ (ជាអ្នកមកពីប្រទេសភូមា ឡាវ និងកម្ពុជា) ហើយកំពុងស្ថិតនៅក្នុងប្រទេសថៃ *(គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៦)*

| សញ្ជាតិ | ចំនួន |
|---|---|
| ភ | 909,916 |
| កម្ពុជា | 111,493 |
| ឡាវ | 44,372 |
| សរុប | 1,065,781 |

*ប្រភព៖ ការិយាល័យរដ្ឋបាលកម្មករបរទេស, នាយកដ្ឋានការងារ, ក្រសួងការងារ*

តារាងទី៣៖ ចំនួនពលករចំណាកស្រុកដែលមានសិទ្ធិធ្វើការដោយស្របច្បាប់ដែលធានាក្រោមមូលនិធិសន្តិសុខសង្គម (គិតត្រឹមខែកុម្ភៈ ឆ្នាំ២០១៦)

| សញ្ជាតិ | ចំនួន |
|---|---|
| មីយ៉ាន់ម៉ា | 319,131 |
| ឡាវ | 12,367 |
| កម្ពុជា | 85,097 |
| វៀតណាម | 521 |
| ផ្សេងៗ | 89,982 |
| សរុប | 507,098 |

*ប្រភព៖ ការិយាល័យសន្តិសុខសង្គម, ក្រសួងការងារ*

**តារាងទី៤៖ ចំនួនពលករចំណាកស្រុក (ទំបបពាក់កណ្ដាលស្របច្បាប់ និង ស្របច្បាប់) ដែលធានាដោយផែនការធានារ៉ាប់រងដែលផ្ដល់ដោយក្រសួងសុខាភិបាលសាធារណៈ (គិតត្រឹមខែតុលា ឆ្នាំ២០១៥)**

| សញ្ជាតិ | ចំនួន |
|---|---|
| មីយ៉ាន់ម៉ា | 659,730 |
| កម្ពុជា | 496,797 |
| ឡាវ | 121,079 |
| **សរុប** | **1,277,606** |

*ប្រភព៖ ក្រុមការងារធានារ៉ាប់រងសុខភាព, ក្រសួងសុខាភិបាលសាធារណៈ*

*កំណត់ហេតុព័ត៌មានពលករចំណាកស្រុក បានផលិតដោយ កម្មវិធីការងារពលករចំណាកស្រុក នៃអង្គការ IOM ប្រចាំព្រះរាជាណាចក្រថៃ។*

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងពួកយើងតាមរយៈលេខទូរសព្ទ៖ 02-3439300, ទូរសារ៖ 02-3439399, ឬអ៊ីម៉ែល៖ migrantnews@iom.int*

*កំណត់ហេតុព័ត៌មានពលករចំណាកស្រុក មានជាអនឡាញនៅឯ http://th.iom.int/index.php/component/remository/facilitating-migration/migration-information-notes/*